សម្លេងខ្មែរនៅបរទេស

# ទស្សនៈ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ វត្តខ្មែរកាណាដា អំពីបំណងដាក់រាជ្យ របស់ព្រះមហាក្សត្រប្រទេសកម្ពុជា

ថ្ងៃទី៣០ សីហា ២០០៤

ជាច្រើនសប្តាហ៍មកហើយ ដែលអ្នកនយោបាយនិងអ្នកច្បាប់បាន ឲ្យយោបល់ផ្សេងៗគ្នា អំពីការសុំដាក់រាជ្យនៃព្រះមហាក្សត្រខ្មែរ ។ អ្នកខ្លះប្រកាន់គោលជំហរថា ព្រះមហាក្សត្រពុំអាចដាក់រាជ្យបានទេ ព្រោះពុំមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ខ្លះពោលថា គ្មានមាត្រាណាក្នុងរដ្ឋធម្មនុញ្ញ ដែលខាឃាំងព្រះមហាក្សត្រមិនឲ្យដាក់រាជ្យទេ ។ ខ្លះពោលថា ត្រូវធ្វើវិសោធនកម្មកែប្រែមាត្រាខ្លះក្នុងរដ្ឋធម្មនុញ្ញ ដើម្បីឲ្យបានច្បាស់លាស់ ។ តទៅនេះ សូមរួមបញ្ចេញទស្សនៈដូចតទៅ ៖

តាមការសង្កេត អ្នកខ្លះបញ្ចេញយោបល់តាមនីតិវិធី ដោយយោលតាមរដ្ឋធម្មនុញ្ញ អ្នកខ្លះបញ្ចេញយោបល់ដើម្បីយកចំណេញខាងផ្លូវនយោបាយ ។ ក្នុងមាត្រា៧ ជំពូក២ ស្តីអំពីព្រះមហាក្សត្រ ក្នុងវគ្គមួយចែងថា «ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត» ។ ពិនិត្យមើលមាត្រាឯទៀតចំនួន២៥មាត្រា ចាប់ពីមាត្រា៧ដល់មាត្រា៣០ ពុំឃើញមាត្រាណាមួយដែលហាមមិនឲ្យព្រះមហាក្សត្រដាក់រាជ្យឡើយ ។

ចំពោះពាក្យថា ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ដែលចែងក្នុងមាត្រា៧នោះ តាមអាត្មាយល់មានន័យថា ក្នុងរយៈពេលដែលព្រះមហាក្សត្រកំពុងគង់នៅក្នុងរាជ្យ, ស្តេចដទៃទៀតក្នុងរាជវង្សានុវង្ស ពុំអាចជ្រែករាជ្យបានឡើយ ឬពុំអាចអ្នកនយោបាយណា ឬគណបក្សណាទម្លាក់ព្រះមហាក្សត្រពីរាជបល្ល័ង្កបានឡើយ ។ ត្រង់នេះបានសេចក្តីថា ព្រះមហាក្សត្រមានសិទ្ធិគង់នៅក្នុងរាជសម្បត្តិរហូតសោយទីវង្គត ពុំអាចនរណាមានសិទ្ធិរារាំងក្នុងចន្លោះនោះឡើយ ។ នៅក្នុងមាត្រាទាំងអស់ក្នុងជំពូកព្រះមហាក្សត្រ ពុំឃើញមានមាត្រាណាមួយ ដែលចែងថា ព្រះមហាក្សត្រពុំអាចដាក់រាជ្យបានឡើយ ឬក៏ចែងថា ព្រះមហាក្សត្រត្រូវតែនៅក្នុងរាជសម្បត្តិអស់មួយជីវិត ក៏ពុំមានឃើញចែងដែរ គ្រាន់តែចែងថា ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត គឺថ្វាយសិទ្ធិតាមផ្លូវច្បាប់ បើព្រះអង្គគង់នៅក្នុងរាជ្យ គឺមានសិទ្ធិគង់នៅរហូតសោយទីវង្គត តែបើព្រះអង្គពុំចង់គង់នៅទៅវិញ គឺជាសិទ្ធិរបស់ព្រះអង្គផ្ទាល់ គ្មានខុសច្បាប់ទេ ។ មួយទៀត ច្បាប់ពុំឃើញមានចែងអំពីការដាក់រាជ្យទេ ព្រះមហាក្សត្រអាចដាក់រាជ្យបាន ដោយមូលហេតុយ៉ាងនេះមួយយ៉ាងនោះមួយ ក៏គ្មានចែងដែរ ។ តាមការវិភាគមកនេះ ព្រះមហាក្សត្រអាចដាក់រាជ្យបាន ដោយគ្មានខុសនឹងច្បាប់រដ្ឋធម្មនុញ្ញឡើយ ។ នេះនិយាយអំពីផ្លូវច្បាប់ ទៅនឹងសិទ្ធិព្រះមហាក្សត្រក្នុងការដាក់រាជ្យនេះ តើខុសច្បាប់ ឬមិនខុសច្បាប់ មិនទាន់និយាយអំពីអ្នកខ្លះចង់ឲ្យព្រះអង្គគង់នៅ អ្នកខ្លះចង់ឲ្យព្រះអង្គដាក់រាជ្យនៅឡើយទេ ។ បើក្រុមប្រឹក្សាធម្មនុញ្ញមានឧត្តមគតិឯករាជ្យ អាចដោះស្រាយត្រង់ចំណុចនេះបាន ប៉ុន្តែគេពុំជឿថា ក្រុមប្រឹក្សាធម្មនុញ្ញមានជំហរឯករាជ្យឡើយ គឺពិតជាមានសម្ពាធពីអ្នកនយោបាយ ។ ដូចបានពោលមកហើយ បើព្រះមហាក្សត្រដាក់រាជ្យ ក៏គ្មានកំហុសអ្វីឡើយ ដូច្នេះពុំចាំបាច់កែប្រែរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ជាតិទេ ។ ប៉ុន្តែបើក្រុមខ្លះចង់ធ្វើវិសោធនកម្មកែប្រែ ឬបន្ថែមមាត្រាក្នុងរដ្ឋធម្មនុញ្ញដើម្បីឲ្យច្បាស់ជាងនេះក៏ល្អដែរ ប៉ុន្តែឃើញមានការលំបាកក្នុងការអនុម័តនៅក្នុងរដ្ឋសភា ព្រោះមានគណបក្សខ្លះគាំទ្រ គណបក្សខ្លះប្រឆាំងចំពោះសំណើនេះ ។ ដើម្បីឲ្យបានសច្ចានុម័តចំពោះវិសោធនកម្មនេះ លុះត្រាតែសមាជិកសភា២ភាគ៣បានអនុម័ត ។ មួយទៀត មិនត្រឹមតែធ្វើច្បាប់ថ្វាយព្រះមហាក្សត្រ អាចមានសិទ្ធិដាក់រាជ្យបាន បើព្រះអង្គមានព្រះបំណងនោះទេ គឺត្រូវធ្វើច្បាប់ដោយចែងឲ្យច្បាស់លាស់ចំពោះការជ្រើសរើសព្រះមហាក្សត្រ ដែលត្រូវគ្រងរាជ្យបន្ត និងព្រះមហាក្សត្រដែលបានដាក់រាជ្យ តើត្រូវរៀបចំកន្លែងប្រថាប់របស់ព្រះអង្គឲ្យបានសុខសាន្តបែបណា ។ ប្រធានាធិបតីបារាំងដែលផុតអាណត្តិ គេមានច្បាប់ចាត់ចែងឲ្យមានគេហស្ថានយ៉ាងប្រណីត គ្រឿងឧបភោគបរិភោគយ៉ាងគ្រប់គ្រាន់ ថែមទាំងផ្តល់អ្នកការពារសន្តិសុខឲ្យរក្សាសន្តិសុខជូនអតីតប្រធានាធិបតីថែមទៀតផង ។

គ្រប់ស្ថាប័នទាំងអស់ត្រូវតែមានច្បាប់ ដូចជាស្ថាប័នព្រះមហាក្សត្រត្រូវតែមានច្បាប់ចែងឲ្យបានច្បាស់លាស់ ដូចជាច្បាប់ជ្រើសរើសព្រះមហាក្សត្រជាដើម ។ ប៉ុន្តែរាល់ពេលដែលសមាជិកសភាម្នាក់បានស្នើឲ្យមានច្បាប់ជ្រើសរើសព្រះមហាក្សត្រ អ្នកកាន់អំណាចខ្មែរបច្ចុប្បន្នតែងតែជំទាស់ដោយពោលថា ការគិតគូរអំពីច្បាប់ជ្រើសរើសព្រះមហាក្សត្រនៅពេលដែលព្រះមហាក្សត្រកំពុងមានព្រះជន្មរស់នៅនេះ គឺជាការប្រមាថមើលងាយព្រះជន្មព្រះមហាក្សត្រ ។ ការរារាំងនេះជាល្បិចនយោបាយ ដើម្បីទាញយកប្រយោជន៍ពីរយ៉ាង គឺប្រយោជន៍ម៉្យាង ធ្វើយ៉ាងណាកុំឲ្យបង្កើតច្បាប់បាន ស្រណុកនៅពេលដែលព្រះមហាក្សត្រអស់ព្រះជន្មទៅ ងាយគេបង្វិលទៅតាមទិសដែលគេចង់បាន បើមានច្បាប់រវល់តែនៅក្រោមច្បាប់ បើធ្វើឲ្យខុសច្បាប់ នាំឲ្យគេចោទថារំលោភច្បាប់ បើកែច្បាប់រឹតតែពិបាកទៅទៀត ។ មាត្រា១៣ ជំពូក២ ស្តីអំពីព្រះមហាក្សត្រមានចែងថា ក្រុមប្រឹក្សារាជសម្បត្តិមានសមាជិក៦រូប ជាអ្នកជ្រើសរើសព្រះមហាក្សត្រ គឺនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភាទី១ និងទី២នៃរដ្ឋសភា ទាំង៤រូបនេះជាអ្នកនយោបាយ សូម្បីព្រះសង្ឃរាជទាំងពីគណៈពីររូបទៀត ក៏ជាអ្នកប្រកាន់គណបក្សនីមួយៗ ពុំឃើញមានអ្នកកណ្តាល អ្នកអព្យាក្រឹត្យឡើយ ។ ដូច្នេះគេអាចជ្រើសរើសស្តេចណាដែលបំរើនយោបាយបក្ស ពុំបំរើនយោបាយជាតិឡើយ ។ ទីពីរដោយព្រះមហាក្សត្រខ្មែរបច្ចុប្បន្ននេះ តែងតែគាំទ្រនយោបាយអ្នកកាន់អំណាច ពុំដែលប្រឆាំងតាំងពីឆ្នាំ១៩៩៣មក រហូតព្រះមហាក្សត្រពោលថា បើគ្មានអ្នកកាន់អំណាចរូបនេះទេ ប្រៀបដូចមនុស្សលោកគ្មានព្រះចន្ទ ។ បើនិយាយតាមរបៀបកុម្មុយនិស្ត របបរាជានិយមគេពុំឲ្យមានទេ ប៉ុន្តែបដិវត្តន៍ជាដំបូងគេធ្វើសន្សឹមៗ បន្ថយឥទ្ធិពលស្តេចបន្តិចម្តងៗ ដូចជាព្រះមហាក្សត្រនៅប្រទេសលាវ ពេលលាវកាន់របបកុម្មុយនិស្ត គេឲ្យព្រះមហាក្សត្រនិងព្រះរាជវង្សានុវង្ស រស់នៅមួយកន្លែងដូចរាស្ត្រសាមញ្ញ គេមិនបំបាត់ទេ ប៉ុន្តែគេមិនឲ្យអំណាច រស់នៅចាស់ជរាសុគតជាបន្តបន្ទាប់គ្នា ចំណែកចាស់គេមិនគោរព ចំណែកថ្មីគេមិនបង្កើត ប្រទេសលាវដែលធ្លាប់ជារាជានិយម ក៏ត្រូវរលត់ត្រឹមនេះហោង ។ ក្រឡេកមកមើលប្រទេសកម្ពុជាវិញ តើមានសភាពយ៉ាងណាដែរ បើយោងតាមរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ត្រង់មាត្រា១ចែងថា ប្រទេសកម្ពុជាជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យពហុបក្ស ។ ដូច្នេះរដ្ឋធម្មនុញ្ញនេះកើតចេញពីសភាធម្មនុញ្ញ ដែលជាតំណាងប្រជាពលរដ្ឋ ទោះបីពេលនេះប្រជាពលរដ្ឋពុំបានបោះឆ្នោតដោ-

យផ្ទាល់ក៏ដោយ ប៉ុន្តែសមាសភាពបានចេញមកពីគ្រប់គូភាគីខ្មែរទាំងអស់ ។ ផ្ទុយទៅវិញ អ្នកកាន់អំណាចខ្មែរបច្ចុប្បន្ននេះពោលថា គេពុំចង់ធ្វើស្តេចទេ ប៉ុន្តែគេជាអ្នកបង្កើតស្តេច ។ បានសេចក្តីថា ព្រះមហាក្សត្រដែលកើតមានសព្វថ្ងៃនេះ ដោយសារគេឧបត្ថម្ភមិងបង្កើតឲ្យមាន ។ តាមន័យនេះ, បើគេបង្កើតស្តេច គេក៏អាចរំលាយស្តេចបានដែរ ។ មាត្រា១៧នៃរដ្ឋធម្មនុញ្ញចែងថា «ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាច មិនអាចសុំកែប្រែជាដាច់ខាត» ។ ប៉ុន្តែបើអ្នកកាន់អំណាច បើគេចង់ធ្វើនៅតែធ្វើបាន គឺគេមិនធ្វើវិសោធនកម្មត្រង់មាត្រានេះទេ គឺគេធ្វើរដ្ឋធម្មនុញ្ញបន្ថែមទី៣ ហើយព្យួរទុកត្រង់ជំពូកព្រះមហាក្សត្រដូចរដ្ឋធម្មនុញ្ញបន្ថែមទី២ បោះឆ្នោតជាកញ្ចប់ដូច្នោះដែរ គឺគេពុំខ្វីរវល់ចំពោះជនណា ឬក្រុមណាជំទាស់បែបណាក៏ដោយ ក៏ពុំអាចធ្វើអ្វីគេកើតឡើយ ។ អ្នកដែលគិតពីបក្សខ្លាំងពេកទៅ អ្វីមួយដែលនៅមានប្រយោជន៍ដល់បក្ស ទើបគេនៅគាំទ្រ ប៉ុន្តែបើអស់ប្រយោជន៍បក្សហើយ ទោះបីនៅមានប្រយោជន៍ជាតិ គេត្រូវតែបោះបង់ចោលដែរ ។

ព្រះមហាក្សត្រខ្មែរមានព្រះបំណងចង់ដាក់រាជ្យ តាមអាត្មាយល់មានមូលហេតុពីរយ៉ាង គឺទី១ព្រះអំណាចរបស់ព្រះអង្គកាន់តែចុះខ្សោយទៅៗ សូម្បីព្រះអង្គបំពេញកិច្ចតាមតែរដ្ឋធម្មនុញ្ញ ក៏អ្នកនយោបាយមិនស្តាប់ដែរ ដូចជាព្រះអង្គសុំឲ្យគេឈប់ចោទប្រកាន់ក្រុមនិស្សិត ដែលរដ្ឋាភិបាលចោទថា បានប្រើអំពើហឹង្សានៅពេលធ្វើបាតុកម្ម ក៏គេពុំគោរពតាម ។ ផ្ទុយទៅវិញ បើរដ្ឋាភិបាលសំរេចពីបញ្ហាអ្វីមួយ ព្រះមហាក្សត្រពុំដែលជំទាស់ តែងតែចុះហត្ថលេខាតាមសេចក្តីសំរេចរបស់រដ្ឋាភិបាលជាដរាប ។ ទី២ព្រះមហាក្សត្រខ្មែរចង់ឃើញផ្ទាល់ព្រះនេត្រ តើព្រះមហាក្សត្រអង្គណា ដែលត្រូវស្នងរាជ្យបន្តពីព្រះអង្គ តើមានច្បាប់ជ្រើសរើសព្រះមហាក្សត្របែបណា ? បើដំណើរការណ៍ស្តេចគ្រងរាជ្យមានដំណើរល្អហើយ ដូចចាស់បូរាណខ្មែរពោលថា ព្រះអង្គសុគតទៅបិទព្រះនេត្រជិត ។ បានសេចក្តីថា រាជានិយមគេនៅតែបន្តឲ្យមានតទៅទៀត ។ ព្រះអង្គសង្ស័យថា ក្រែងអត់ពីព្រះអង្គទៅ គេប្រកាសសាធារណរដ្ឋ ព្រោះសព្វថ្ងៃនេះព្រះអង្គនៅមានឥទ្ធិពល ទើបគេនៅទុកសិន ។ នេះគ្រាន់តែជាការប៉ាន់ប្រមាណមើលទេ ប៉ុន្តែជំរៅព្រះទ័យអាថ៌កំបាំងរបស់ព្រះអង្គផ្សេងពីនេះទៀត យើងពុំអាចដឹងបានទេ ។

មានគេសួរយោបល់អាត្មាថា តើតទៅអនាគត ប្រទេសកម្ពុជាត្រូវតែនៅជារាជានិយម ឬក៏ផ្លាស់ទៅជាសាធារណរដ្ឋវិញ ដើម្បីឲ្យប្រទេសកម្ពុជាលូតលាស់ចំរើន ? អាត្មាឆ្លើយថា ការផ្លាស់ប្តូររបបជាបញ្ហាធំណាស់ ពុំមែនមនុស្សម្នាក់ពីរនាក់ផ្លាស់បានទេ តាមរបបប្រជាធិបតេយ្យ គឺស្ថិតនៅលើប្រជាពលរដ្ឋទាំងអស់ដែលស្ថិតនៅក្នុងប្រទេស ។ ក្រៅពីនោះមានតែរបបផ្តាច់ការ ឬរដ្ឋប្រហារទេ ដែលអាចប្តូររបបពីមួយទៅមួយបាន គឺគេធ្វើក្រៅច្បាប់ ក្រៅពីមតិនិងឆន្ទៈប្រជាពលរដ្ឋ ។ ដូចប្រទេសខ្លះ បើអ្នកកាន់អំណាចចង់កាន់ការមួយជីវិត គេត្រូវដូររដ្ឋធម្មនុញ្ញជារបបផ្តាច់ការ ជាពិសេសរបបកុម្មុយនិស្ត ប្រធានមជ្ឈិមបក្សកាន់ការរហូតដល់ស្លាប់ ។ ប៉ុន្តែបច្ចុប្បន្ននេះ លទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស កាន់តែមានចលនាទៅមុខយ៉ាងលឿន ចំណែករបបផ្តាច់ការរបបដែលពុំគោរពឆន្ទៈរបស់ប្រជាពលរដ្ឋ កាន់តែដួលរលំមួយម្តងៗ ស្ទើរតែអស់ក្នុងពិភពលោក ។ យ៉ាងណាមិញ ប្រទេសកម្ពុជាកំពុងឈានមករកលទ្ធិប្រជាធិបតេយ្យហើយ ដូច្នេះដំណោះស្រាយអ្វីមួយ ជាពិសេសបញ្ហាធំៗរបស់ជាតិ ត្រូវតែធ្វើតាមលទ្ធិប្រជាធិបតេយ្យ តាមរយៈសន្លឹកឆ្នោតដោយសេរីនិងយុត្តិធម៌ ដែលជាការឆ្លុះបញ្ចាំងពិតប្រាកដនៃឆន្ទៈប្រជាពលរដ្ឋដែលជាម្ចាស់អំណាច ។ ប៉ុន្តែរបបផ្តាច់ការច្រើនយកឈ្មោះប្រជាជនមកប្រើ ដើម្បីបិទបាំងគំនិតផ្ទាល់ខ្លួនគេពីរបីនាក់ ថាជាគំនិតប្រជាជនទូទៅ ។ គេច្រើនប្រើអំពើហឹង្សា ព្រោះបើគេប្រើកម្លាំងច្បាប់គេនឹងទទួលបរាជ័យ ។ ប្រជាពលរដ្ឋជាសមាជិកសង្គម ដែលជាធនធានដ៏សំខាន់សំរាប់សាងសង្គមឲ្យលូតលាស់ចំរើន ។ ដូច្នេះប្រជាពលរដ្ឋជាអ្នកដឹកនាំសង្គម តាមរយៈតំណាងរបស់ខ្លួន គឺរដ្ឋសភា ដើម្បីបង្កើតរដ្ឋាភិបាល ។ ដើម្បីឲ្យការដឹកនាំនេះមានវឌ្ឍនភាព សន្តិភាព និងយុត្តិធម៌ ប្រជាពលរដ្ឋត្រូវមានការសិក្សាច្រើន ហើយមានការពិសោធន៍ផង ទើបសំរេចបានជាផលល្អ ជាពិសេសផលល្អត្រង់ចម្លើយទៅនឹងសំនួរខាងដើមថា តើប្រទេសកម្ពុជានៅជារាជាណាចក្រ ឬទៅជាសាធារណរដ្ឋនៅពេលអនាគត ។ បញ្ហានេះ ប្រជាពលរដ្ឋខ្មែរជាអ្នកសំរេច ព្រោះប្រជាពលរដ្ឋជាម្ចាស់អំណាច ។៚